# ឧទ្ទេសនាមសង្ខេបអំពីការដកដំណែង

ប្រការទី 17 នៃរដ្ឋធម្មនុញ្ញបានកំណត់៖ "ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត, សិទ្ធិដកដំណែង, សិទ្ធិបង្កើតយន្តការ, សិទ្ធិផ្តល់សំឡេង", ប្រការទី 133 បានកំណត់៖ "អ្នកដែលបានជ្រើសតាំង គឺអាស្រ័យតំបន់បោះឆ្នោតដំបូងដកដំណែងស្របតាមច្បាប់", ដកដំណែង គឺជាសិទ្ធិនយោបាយមូលដ្ឋានបានរដ្ឋធម្មនុញ្ញកំណត់ជូនពលរដ្ឋ។ ផលប៉ះពាល់នៃសិទ្ធិបោះឆ្នោត ស្ថិតនៅលើការជ្រើសរើសអ្នកស្លូតបូតឈ្លាសវៃ និងមានបញ្ញា, ការបង្កើតសិទ្ធិដកដំណែង គឺដើម្បីកម្មាភិបាលដែលពលរដ្ឋបានជ្រើសតាំង អាចមានមនសិការៈ មានមុខងារសង្កេត និងផ្លាស់ប្តូរនូវកម្មាភិបាលដែលបានជ្រើសតាំងហើយតែមិនសមស្របនឹងភារៈកិច្ច។ ឆ្លងតាមការអនុវត្តសិទ្ធិបោះឆ្នោត សិទ្ធិដកដំណែង, នយោបាយអាចបង្អែកលើប្រជាមតិ, អនុវត្តនយោបាយប្រជាធិបតេយ្យពិតប្រាកដ។

យន្តការដកដំណែងកម្មាភិបាលជាធរមាននៃប្រទេសយើង គឺវៀរលែងចំពោះ សមាជិកអ្នកបង្កើតច្បាប់, ពលរដ្ឋដែលរស់នៅក្រៅប្រទេស ហើយក៏មិនបានបែងចែកតំបន់រស់នៅដែរ អ្នកទាំងនោះមិនអនុវត្តនូវសេចក្តីកំណត់អំពីការដកដំណែង, ការដកដំណែងកម្មាភិបាលដែលពលរដ្ឋបានជ្រើសតាំង សុទ្ធតែបានអ្នកបោះឆ្នោតនៅតំបន់បោះឆ្នោតបានតែងតាំង, ចំនួនអ្នកតែងតាំងត្រូវមានអត្រាខ្ពស់ជាង 1% ក្នុងចំនួនអ្នកបោះឆ្នោតរួមនៅតំបន់បោះឆ្នោតនោះ និងមានហត្ថលេខាបញ្ជាក់។ អ្នកដែលចុះហត្ថលេខាត្រូវមានចំនួនជាង 10% ក្នុងចំនួនអ្នកបោះឆ្នោតនៃតំបន់បោះឆ្នោត, ប្រធានគណៈកម្មាធិការបោះឆ្នោតប្រកាស និងបង្កើតការដកដំណែង។ តែប្រសិនបើអ្នកត្រូវដកដំណែងនោះមានការទទួលបន្ទុកភ្នាក់ងារមិនទាន់គ្រប់ 01 ឆ្នាំ គឺមិនអាចស្នើអោយមានការដកដំណែងបានទេ។ លទ្ធផលបោះឆ្នោតដកដំណែង, ចំនួនឆ្នោតយល់ព្រមមានប្រសិទ្ធភាពចំពោះការដកដំណែងត្រូវមានច្រើនជាងចំនួនឆ្នោតបដិសេធន៍ ហើយចំនួនឆ្នោតយល់ព្រមត្រូវមានអត្រាច្រើនជាងមួយភាគបួន នៃចំនួនរួមអ្នកដែលបោះឆ្នោតក្នុងតំបន់បោះឆ្នោតដំបូង គឺបានអនុម័តិ។